01068477



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception):
23 / 01 / 2015
ម៉ោង (Time/Heure) : 14:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

ថ្ងៃ ពុធ ទី ២១ ខែ មករា ឆ្នាំ ២០១៥

**សវនាការលើកភស្តុតាង - ថ្ងៃ ២៣០**

រៀបចំដោយ៖ **ជា ស៊ីវហ៊ាង** និង **Matthew McCARTHY**

| **កំណត់ហេតុអ្នកចូលរួម** |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យ៉ា សុខន, ចៅក្រម Claudia FENZ, ចៅក្រម ធូ មណី |
| ចៅក្រមបម្រុង៖ ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, កញ្ញា ជា ស៊ីវហ៊ាង, លោក Matthew J. McCARTHY |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក Nicholas KOUMJIAN, លោក សេង លាង, លោក Travis FARR, លោក Dale LYSAK, លោក Salim NAKHJAVANI |
| ជនជាប់ចោទ៖ លោក នួន ជា, លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Victor KOPPE |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជអង្គ, លោកស្រី Marie GUIRAUD, លោក ឡោ ជុនធី, លោក វេីន ពៅ, លោកស្រី ជេត វណ្ណលី, លោកស្រី ទី ស្រ៊ីនណា , លោក Yiqiang LIU |

| |
|---|
| សាក្សី/ដើមបណ្ដឹង៖ មាស សុខា ហៅ ផ្លាង (2-TCW-936) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ, លោកស្រី សួ សុទ្ធារី |
| ផ្សេងៗ៖ លោក NOU Monoroath (អ្នកបកប្រែភាសា), លោក Sheriffo JAMMEH, កញ្ញា ស្រី ណាក់, កញ្ញា Kerri MILES, លោក ហ៊ូ ជីសេង, កញ្ញា Sara ERJAVEC |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៥ | ចាប់ផ្ដើមម៉ោង៖ ០៩.០២ | បញ្ចប់ម៉ោង៖ ១៦.០៣ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ០៩.២៥ | បញ្ចប់ម៉ោង៖ ១០.០០ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១២.០៧ | បញ្ចប់ម៉ោង៖ ១៣.៣៥ |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ ១៤.៣៦ | បញ្ចប់ម៉ោង៖ ១៤.៥៨ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៤ ម៉ោង និង ២៦ នាទី |

| **កិច្ចដំណើរការនីតិវិធីផ្សេងទៀត** | | | |
|---|---|---|---|
| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០២ | ០៩.០៥ |
| បញ្ហាសម្បទារបស់ជនជាប់ចោទ | អង្គជំនុំជម្រះ | ០៩.០៥ | ០៩.០៧ |
| ការបញ្ជាក់ពីតួនាទីរបស់មេធាវីប្រចាំការ | អង្គជំនុំជម្រះ | ០៩.០៨ | ០៩.១២ |
| សំណើរបស់សហមេធាវីនាំមុខ ស្នើសុំឱ្យទទួលយកជាភ័ស្តុតាងនូវឯកសារផែនទីថ្មី | អង្គជំនុំជម្រះ | ០៩.១២ | ០៩.១៣ |
| សំណើរបស់សហមេធាវីនាំមុខពាក់ព័ន្ធនឹងការសុំតាំងសំនួរទៅកាន់អ្នកជំនាញ | អង្គជំនុំជម្រះ | ០៩.១៣ | ០៩.១៤ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើការនីតិវិធីពីបន្ទប់ឃុំខ្លួនក្រោមសាលសវនាការ | មេធាវីការពារក្ដី នួន ជា<br>អង្គជំនុំជម្រះ | ០៩.២១<br>០៩.២២ | ០៩.២២<br>០៩.២៣ |
| ការពន្យាកិច្ចដំណើរនីតិវិធី | អង្គជំនុំជម្រះ | ០៩.២៥ | ១០.០០ |
| ការបន្តតាំងសំណួរទៅកាន់សាក្សី មាស សុខា (2-TCW-936) | សហព្រះរាជអាជ្ញា<br>អង្គជំនុំជម្រះ | ១០.០០<br>១១.៣៩ | ១១.៣៨<br>១២.០៦ |

| | | | |
|---|---|---|---|
| | សហមេធាវីនាំមុខ<br>មេធាវីការពារក្តី នួន ជា | ១៣.៣៦<br>១៤.០១ | ១៤.០១<br>១៦.០១ |
| ការបដិសេធទៅលើយថាភាពនៃឯកសារដែលបានស្នើ | មេធាវីការពារក្តី នួន ជា | ១០.៣៧ | ១០.៤៧ |
| សំណើសុំផ្អាកសវនាការ | មេធាវីការពារក្តី ខៀវ សំផន | ១៥.៤៦<br>១៦.០១ | ១៥.៤៩<br>១៦.០២ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី**

ប្រធានអង្គជំនុំជម្រះប្រកាសថា ចៅក្រម ធូ មណី ដែលជាចៅក្រមបម្រុង នឹងជំនួសចៅក្រម យ៉ូរ ឧត្តរា រហូតដល់ពេល គាត់មានវត្តមានវិញ។ ក្រឡាបញ្ជីរាយការណ៍ថា ភាគីទាំងអស់មានវត្តមាន។

**បញ្ហាសម្បទារបស់ជនជាប់ចោទ**

អង្គជំនុំជម្រះកត់សម្គាល់ថា បន្ទាប់ពីអ្នកជំនាញវាយតម្លៃផ្នែកវេជ្ជសាស្ត្ររួចហើយ អង្គជំនុំជម្រះកំណត់ថាសវនាការលើសម្បទារបស់ជនជាប់ចោទ នឹងធ្វើឡើងនៅថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥។ អង្គជំនុំជម្រះបានបង្គាប់ឲ្យភាគីទាំងអស់ជូនដំណឹងមកអង្គជំនុំជម្រះ ត្រឹមម៉ោង ៣.០០ រសៀល ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ ថាតើខ្លួនមានបំណងចង់ឲ្យមានសវនាការលើសម្បទារបស់ជនជាប់ចោទ ដែរឬទេ។

**ការបញ្ជាក់ពីតួនាទីរបស់មេធាវីប្រចាំការ**

អង្គជំនុំជម្រះរម្លឹកដល់ភាគីថា ខ្លួនបដិសេធចោលសំណើសុំឲ្យពិចារណាឡើងវិញលើសេចក្តីសម្រេចតែងតាំងមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន ដោយសារពុំមានកាលៈទេសៈថ្មី ឬ ទម្លើករណ៍ថ្មីណាមួយបានលើកឡើងនោះទេ។ អង្គជំនុំជម្រះក៏សម្រេចបដិសេធចោលសំណើសុំឲ្យកែប្រែទីកន្លែងអង្គុយក្នុងសាលសវនាការផងដែរ។ប្រធានអង្គជំនុំជម្រះសង្ខេបនូវតួនាទីរបស់មេធាវីប្រចាំការ។

**សំណើរបស់សហមេធាវីនាំមុខស្នើសុំឲ្យទទួលយកជាភស្តុតាងនូវឯកសារផែនទីថ្មី**

អង្គជំនុំជម្រះបានធ្វើការបដិសេធចោលនូវសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលសុំអោយទទួលយកផែនទីដែលជាឯកសារថ្មីធ្វើជាភស្តុតាង ដែលខ្លួនមានបំណងចង់ប្រើប្រាស់ឯកសារនោះក្នុងការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-296។ អង្គជំនុំជម្រះបញ្ជាក់ថា ឯកសារនោះមិនមានប្រយោជន៍ក្នុងការស្វែងរកការពិតនោះទេ។

**<u>សំណើរបស់សហមេធាវីនាំមុខពាក់ព័ន្ធនឹងការសុំតាំងសំនួរទៅកាន់អ្នកជំនាញ</u>**

អង្គជំនុំជម្រះបញ្ជាក់ថា ស្របតាមការអនុវត្តពីមុន សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវបានអនុញ្ញាតិឲ្យតាំងសំនួរទៅកាន់អ្នកជំនាញដែលត្រូវបានតែងតាំងដោយអង្គជំនុំជម្រះ។

**<u>សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើការនីតិវិធីពីបន្ទប់ឃុំខ្លួនក្រោមសាលសវនាការ</u>**

មេធាវីការពារក្តី នួន ជា បានស្នើសុំឲ្យជនជាប់ចោទ នួន ជា តាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ អង្គជំនុំជម្រះកត់សម្គាល់ថា ជនជាប់ចោទ នួន ជា បានលះបង់សិទ្ធិរបស់ខ្លួនក្នុងការមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ។ អង្គជំនុំជម្រះបានអនុញ្ញាតតាម សំណើ។

**<u>ការពន្យាកិច្ចដំណើរនីតិវិធី</u>**

នៅវេលាម៉ោង ០៩.២៥ កិច្ចដំណើរការនីតិវិធីសវនាការត្រូវបានផ្អាកអស់រយៈពេល ៣៥ នាទី ដោយសារតែមានបញ្ហាផ្នែកបច្ចេកទេស ដោយមេក្រូរបស់សហព្រះរាជអាជ្ញាមិនដំណើរការ។

**<u>ការបន្តតាំងសំណួរទៅកាន់សាក្សី មាស សុខា (2-TCW-936)</u>**

សហ ព្រះរាជអាជ្ញាបន្តតាំងសំណួរទៅកាន់សាក្សី ហើយបន្ទាប់មកអង្គជំនុំជម្រះ និងសហមេធាវីនាំមុខតាំងសំណួរ។ បន្ទាប់មកមេធាវីការពារក្តី នួន ជា ចាប់ផ្តើមតាំងសំណួរ។ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សីនេះបញ្ចប់នៅថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥។

**<u>ការបដិសេធទៅលើយថាភាពនៃឯកសារដែលបានស្នើ</u>**

មេធាវីការពារក្តី នួន ជា បានជំទាស់ទៅនឹងយថាភាពនៃឯកសារដែលសហព្រះរាជអាជ្ញាបានស្នើ ឡើង (ឯកសារ E3/4095)។ អង្គជំនុំជម្រះបានបដិសេធចោលសំណើនេះ ដោយសារសំណើលើកឡើងមិនទាន់ពេលវេលា។

**<u>សំណើសុំផ្អាកសវនាការ</u>**

មេធាវីការពារក្តី ខៀវ សំផន បានស្នើសុំផ្អាកកិច្ចដំណើការនីតិវិធីសវនាការ ឬបើមិនដូច្នោះ ស្នើឲ្យអនុញ្ញាតិឲ្យជនជាប់ចោទ ខៀវ សំផន អាចតាមដានកិច្ចដំណើការនីតិវិធីពីបន្ទប់ឃុំខ្លួនក្រោមសាលសវនាការ ដោយសារបញ្ហាសុខភាពជនជាប់ចោទ ខៀវ សំផន ដោយលោកមានការនឿយហត់ខ្លាំង។

អង្គជំនុំជម្រះអនុញ្ញាតិឲ្យជនជាប់ចោទ ខៀវ សំផន តាមដានកិច្ចដំណើការនីតិវិធីពីបន្ទប់ឃុំខ្លួនក្រោមសាលសវនាការ។

មេធាវីការពារក្តី ខៀវ សំផន ស្នើសុំឲ្យអង្គជំនុំជម្រះផ្អាកកិច្ចដំណើការនីតិវិធីដោយសារ បញ្ហាសុខភាពរបស់ជនជាប់ ចោទ ខៀវ សំផន។ អង្គជំនុំជម្រះអនុញ្ញាតិ និងផ្អាកកិច្ចដំណើការនីតិវិធី។

**<u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង</u>**

| លេខ E3 | លេខ កសចស | ERN (KH, ENG, FR) | ចំណងជើងឯកសារ | ចំណាត់ថ្នាក់ | ERN ខ្មែរ | ERN អង់គ្លេស | ERN បារាំង |
|---|---|---|---|---|---|---|---|
| E3/5825 | D25/31 | 00163510-00163519<br>00223493-00223502<br>00178110-00178117 | Written Record of Interview of MEAS Sokha | P | 00167511<br>00163513<br>00163514<br>00163515<br>00163516<br>00163518 | 00223495<br>00223496<br>00223497<br>00223499<br>00223500<br>00223501 | 00178112<br>00178113<br>00178114<br>00178115<br>00178116<br>00178117 |
| E3/5826 | D25/30 | 00163503-00163509<br>00223486-00223492<br>00178422-00178427 | Written Record of Interview of HUN Kimseng | P | 00163506<br>00263507<br>00263508 | 00223489<br>00223490<br>00223491 | 00178425<br>00178426<br>00178427 |
| E3/4095 | D157.17 | 00271089-00271131<br>00747236-00747298<br>00721205-00721272 | 5th Confession entitled "Contemptible Traitors Pol Pot and IENG Sary" | P | 00271089<br>00271098<br>00271101<br>00271102<br>00271106 | 00747250<br>00747254-00747257<br>00747262<br>00747263 | 00721219<br>00721220<br>00721224-00721227<br>00721233<br>00721234 |
| E3/5834 | D232/93 | 00427971-00427981<br>00434687-00434697<br>00434698-00434708 | Written Record of Interview of SREI Than | P | | 00434691<br>00434692 | 00434702<br>00434703 |
| E3/5835 | D25/32 | 00163520-00163527<br>00223503-00223509<br>00178428-00178433 | Written Record of Interview of SOK Sott | P | 00163521<br>00163525 | 00223505<br>00223508 | 00178430<br>00178433 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/4145 | D312.1.51 | 00068730-00068738 00762837-00762847 00761093-00761103 | List of prisoner suggeste to Party to kill (NOTE: typographical error in title of document on Case File.) | P | 00068730 | 00762837 00762844 | 00761093 00761100 |

**<u>ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖</u>**

- បង្គាប់ឲ្យភាគីទាំងអស់ជូនដំណឹងមកអង្គជំនុំជម្រះ ថាតើខ្លួនមានបំណងចង់ឲ្យមានសវនាការលើសម្បទារបស់ជនជាប់ចោទដែរឬទេ ត្រឹមម៉ោង ០៣.០០ រសៀល ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៥ (០៩.០៦)
- បដិសេធចោលនូវសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដែលស្នើដាក់ឯក-សារថ្មីចូលជាភ័ស្ដុតាងដើម្បីប្រើប្រាស់ពេលសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-296 ។ (០៩.១៣)
- សម្រេចអនុញ្ញាតិឲ្យមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសួរសំណួរទៅកាន់ អ្នកជំនាញនៅក្នុងអំឡុងពេលសវនាការលើសម្បទារបស់ជនជាប់ចោទ។ (០៩.១៤)
- អនុញ្ញាតឲ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនក្រោមសាលសវនាការ ហើយបង្គាប់អ្នកជំនាញតំឡើងឧបករណ៍សោធទស្សន៍សម្រាប់ជនជាប់ ចោទ នួន ជា ដើម្បីបន្តតាមដានសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោម។ (០៩.២៣)
- អនុញ្ញតអោយជនជាប់ចោទ ខៀវ សំផន បន្តតាមដានកិច្ចដំណើរនីតិវិធីសវនាការ ពីបន្ទប់ឃុំខ្លួនក្រោមសាលសវនាការ ហើយបង្គាប់អ្នកជំនាញឲ្យតំឡើងឧបករណ៍សោធទស្សន៍សម្រាប់ជនជាប់ចោទ ខៀវ សំផន ដើម្បីបន្តតាមដានសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោម។ (១៥.៤៩)
- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅមន្ទីរឃុំឃាំងវិញ និងបង្គាប់ឲ្យនាំខ្លួន នួន ជា និង ខៀវ សំផន មកសាលសវនាការវិញឲ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥។

| <u>កាលវេលាសវនាការបន្ត</u> |
|---|
| សវនាការនឹងបន្តទៅថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ ចាប់ផ្តើមពីម៉ោង ៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៥

ក្រឡាបញ្ជី ក្រឡាបញ្ជី

**ជា ស៊ីវហួង** **Matthew McCARTHY**